# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

លេខ ០៣៦ អបស.មត

ថ្ងៃអង្គារ ៥ កើត ខែទុតិយាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ២០១៨

**រដ្ឋមន្ត្រីក្រសួងសុខាភិបាល**

**ជម្រាបមក**

**លោក-លោកស្រីម្ចាស់គ្លីនិកឯកជនទាំងអស់**

**កម្មវត្ថុ:** ករណីរំលឹកជាលើកចុងក្រោយដល់ម្ចាស់គ្លីនិកឯកជនដែលមិនគោរពច្បាប់ និងក្រមសីលធម៌វិជ្ជាជីវៈសុខាភិបាល។

**យោង:** លិខិតលេខ០៤៣អបស/មព ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៧ របស់ក្រសួងសុខាភិបាល។

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូម **លោក-លោកស្រីម្ចាស់គ្លីនិកឯកជនទាំងអស់** ជ្រាបថា ក្រសួងសុខាភិបាល សូមធ្វើការរំលឹកជាលើកចុងក្រោយដល់ម្ចាស់គ្លីនិកឯកជនដែលមិនគោរពច្បាប់ស្ដីពីការគ្រប់គ្រងលើការបរិច្ចាគ ការផ្សាំកោសិកា ជាលិកា និងសរីរាង្គ និងក្រមវិជ្ជាជីវៈសុខាភិបាល ព្រមទាំងប្រកាសរបស់ក្រសួងសុខាភិបាល។ ម្យ៉ាងទៀតមានម្ចាស់គ្លីនិកឯកជនមួយចំនួនបាននិងកំពុងតែធ្វើការផ្សព្វផ្សាយព័ត៌មានស្ដីពីសេវាបង្កកំណើតសិប្បនិម្មិត ដែលក្រសួងមិនទាន់បានអនុញ្ញាតច្បាប់ឲ្យដល់គ្លីនិកណាមួយនៅឡើយទេដោយរង់ចាំច្បាប់ស្ដីពីការពពោះជំនួសនិងច្បាប់ស្ដី ពីការគ្រប់គ្រងសេវាសុខាភិបាលកើតឡើង។ផ្ទុយទៅវិញប្រសិនបើម្ចាស់គ្លីនិកនៅតែបន្តសកម្មភាព នឹងត្រូវទទួលទោសតាមច្បាប់ជាធរមាន។

អាស្រ័យហេតុនេះ សូម **លោក-លោកស្រីម្ចាស់គ្លីនិកឯកជន** មេត្តាត្រូវតែគោរពច្បាប់ បទដ្ឋានគតិយុត្តិ និងក្រមវិជ្ជាជីវៈសុខាភិបាលឲ្យមានប្រសិទ្ធភាពខ្ពស់។

សូម **លោក-លោកស្រីម្ចាស់គ្លីនិកឯកជន** មេត្តាទទួលនូវការគោរពរាប់អានអំពីខ្ញុំ។

ជ.រដ្ឋមន្ត្រី

រដ្ឋលេខាធិការ

បណ្ឌ. ម៉ែ_គុយស៊ាង

**ចម្លងជូន:**

- ក្រសួងមហាផ្ទៃ
- ក្រសួងយុត្តិធម៌
- សាលារាជធានី-ខេត្ត (ដើម្បីជាព័ត៌មាន)
- មន្ទីរសុខាភិបាលរាជធានី-ខេត្ត
- គណៈគ្រូពេទ្យជាតិ (ដើម្បីផ្សព្វផ្សាយ ឬអនុវត្ត)
- ឯកសារ-កាលប្បវត្តិ